## 6 ចំណុចដែលត្រូវដឹងអំពីសមិទ្ធិផលនៃការសិក្សា

### តើអ្វីជាសមិទ្ធិផលនៃការសិក្សា?

សមិទ្ធិផលនៃការសិក្សាមានន័យថា ជាចំនួនសិស្សដែលទទួលបានពិន្ទុក្នុងកម្រិតលទ្ធផល 3 ឬ 4 (ស្រប ឬលើសពីសេចក្តីរំពឹងទុករបស់រដ្ឋ) តាមការវាយតម្លៃការអប់រំរបស់រដ្ឋ Maine (MEAs)។

### ហេតុអ្វីបានជាសមិទ្ធិផលនៃការសិក្សាមានសារៈសំខាន់?

ផែនការយុទ្ធសាស្រ្តរបស់រដ្ឋ Maine មានបំណងឲ្យសិស្សបញ្ចប់ការសិក្សាត្រៀមខ្លួនធ្វើការពីវិទ្យាល័យ។ សមិទ្ធិផលនៃការសិក្សា គឺជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធគណនេយ្យភាពរបស់រដ្ឋ។

### ហេតុអ្វីបានជារដ្ឋ Maine តាមដានសមិទ្ធិផលនៃការសិក្សា?

ច្បាប់សហព័ន្ធស្តីពីការជោគជ័យរបស់សិស្សរាល់រូប (ESSA) ទាមទារឱ្យរដ្ឋនីមួយៗមានប្រព័ន្ធគណនេយ្យភាពដែលរួមមានសមិទ្ធិផលនៃការសិក្សាជាអាំងឌីកាទ័រនៃវឌ្ឍនភាព និងភាពជោគជ័យរបស់សាលា។

### តើអ្វីដែលជាគោលដៅសម្រាប់ការជោគជ័យរបស់រដ្ឋ Maine?

ក្រុមសិស្សនីមួយៗដែលមានសិស្សលើសពីដប់នាក់ មានគោលដៅបង្កើនសមិទ្ធិផលនៃការសិក្សា 20% ត្រឹមឆ្នាំ 2030 ។

### តើទិន្នន័យបានមកពីណា?

ទិន្នន័យស្តីពីសមិទ្ធិផលនៃការសិក្សាបានមកពីការវាយតម្លៃការអប់រំរបស់រដ្ឋ Maine (MEAs)។ សម្រាប់ថ្នាក់ទីបីដល់ទីថ្នាក់ប្រាំបី ទិន្នន័យនេះ គឺបានពីការវាយតម្លៃ eMPowerME ទៅលើគណិតវិទ្យា និង ELA ចំណែក SAT ផ្តល់ទិន្នន័យសម្រាប់សិស្សរៀននៅឆ្នាំទី 3 នៃវិទ្យាល័យ។

### តើវានឹងបង្ហាញយ៉ាងណាលើប័ណ្ណរបាយការណ៍សាលា?

សាលារៀននឹងទទួលបានការវាស់ស្ទង់លទ្ធផលមួយអំពី ELA និងគណិតវិទ្យាដែលទាក់ទងទៅនឹងរបៀបដែលក្រុមសិស្សនានាកំពុងសម្រេចតាមសេចក្តីរំពឹងទុករបស់រដ្ឋអំពីសមិទ្ធិផល។